# ការវិភាគយេនឌ័រពីអង្កេតលើយុវជន និងមនុស្សជំនាន់មុននៅកម្ពុជា៖ គ្រួសារ សហគមន៍ ចំណេះដឹង ឥរិយាបថនយោបាយ និងការរំពឹងទុកទៅអនាគត

## សេចក្តីផ្តើម

ប្រទេសកម្ពុជា ឆ្លងតាមកំណើនគួរឲ្យស្ញប់ស្ញែងក្នុងជាងពីរទសវត្សរ៍កន្លងមកនេះ កំពុងក្លាយយ៉ាងលឿនជាខ្លាសេដ្ឋកិច្ចថ្មីមួយនៅអាស៊ី។ កម្ពុជាសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងលឿនគួរស្ញប់ស្ញែងក្នុង ២០ឆ្នាំកន្លងមក ដោយមាន កំណើន ផសស ជាប់រហូតដល់ជាង ៧% ក្នុងមួយឆ្នាំ ការពង្រីកនិងកែលំអហេដ្ឋារចនាសម្ព័ន្ធ និងការជឿនលឿនគួរឲ្យកត់សំគាល់ក្នុងការកាត់បន្ថយភាពក្រីក្រ។ លទ្ធផលសេដ្ឋកិច្ចសង្គមដ៏ល្អជាយូរឆ្នាំមកនេះ បានធ្វើឲ្យមាននគរូបនីយកម្មយ៉ាងលឿន ហើយស្របគ្នានឹងការប្រែប្រួលផ្នែកប្រជាសាស្ត្រ ក៏មានការកែលំអគុណភាពការអប់រំ និងកំណើនដែនគ្របដណ្តប់និងការប្រើប្រាស់អ៊ិនធើណិត ហើយទាំងអស់នេះបានធ្វើឲ្យប្រែប្រួលដល់ចំណាប់អារម្មណ៍ ការគិតគូរ និងអាកប្បកិរិយារបស់ពលរដ្ឋកម្ពុជា ជាពិសេស ក្នុងចំណោមស្ត្រី។

ពិតហើយ ស្ត្រីបានចូលរួមចំណែកយ៉ាងសំខាន់ដល់ការកសាងប្រទេសកម្ពុជាឡើងវិញ ការអភិវឌ្ឍសេដ្ឋកិច្ច និងអនាគតរំពឹងចង់បាន។ ការពន្លឿនសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី ជារឿយៗមានអាទិភាពខ្ពស់នៅក្នុងគម្រោងអភិវឌ្ឍន៍ផ្សេងៗ ជាពិសេស គម្រោងរបស់អង្គការមិនមែនរដ្ឋាភិបាល (NGOs) ក្នុងស្រុក និងអន្តរជាតិនានា។ ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងសមភាពយេនឌ័រ ជាចំណុចផ្តោតសំខាន់របស់រាជរដ្ឋាភិបាល ដូចជាក្នុងការបង្កើត ក្រសួងកិច្ចការនារី នៅឆ្នាំ១៩៩៣ ជាដើម។ ទោះបីប្រជាជនកម្ពុជាមានអារម្មណ៍ផ្សារភ្ជាប់ខ្លួនខ្លាំងជាងតាមខ្សែខាងម្តាយ ហើយស្ត្រីដើរតួនាទីសកម្មទាំងក្នុងគ្រួសារ និងក្នុងសង្គមក្តី ក៏ស្ត្រីនៅតែជួបបញ្ហាប្រឈមក្នុងលទ្ធភាព និងឱកាសដើម្បីជះឥទ្ធិពលទៅលើសេចក្តីសម្រេចចិត្តក្នុងគ្រួសារ ក្នុងសហគមន៍ និង ក្នុងមជ្ឈដ្ឋាននយោបាយ (Baudinet 2018, MOWA 2014,Thon 2017) ។

អត្ថបទនេះសង្ខេបលទ្ធផលការវិភាគយេនឌ័រ (Un, Saphon and Sok 2019) នៃអង្កេតតំណាងឲ្យទូទាំងប្រទេសដែលរៀបចំឡើងដោយផ្នែកអភិបាលកិច្ច នៃវិទ្យាស្ថាន CDRI សម្រាប់ការស្រាវជ្រាវស្តីពី "យុវជន និងមនុស្សជំនាន់មុននៅកម្ពុជា៖ ទំនាក់ទំនងរវាងទាំងពីរជំនាន់ និងទស្សនៈសង្គម និងនយោបាយ" (Eng et al. 2019)។ ការសិក្សា និងការវិភាគយេនឌ័រ ជាទូទៅផ្តោតលើស្ថានភាពរបស់ស្ត្រី ឬចំណាប់អារម្មណ៍របស់ស្ត្រីលើបញ្ហាខ្លះ ដោយសន្មតថា ស្ត្រីទាំងអស់មានលក្ខណៈដូចគ្នា។ ប៉ុន្តែការវិភាគយេនឌ័រនេះមានចំណុចពិសេសមួយ គឺមិនបានចាត់ទុកស្ត្រីជាមនុស្សមួយក្រុម មានលក្ខណៈដូចគ្នាទាំងអស់នោះទេ។ ផ្ទុយទៅវិញ ការវិភាគនេះបានពិនិត្យលើ អន្តរកម្មនិងទំនាក់ទំនង ហើយនិង កត្តាផ្សេងទៀតដែលនាំឲ្យមាន ភាពខុសគ្នារវាងស្ត្រីនឹងស្ត្រី និងភាពខុសគ្នារវាងស្ត្រីនឹងបុរស ដោយធ្វើការបំបែកទិន្នន័យលើលក្ខណៈសម្បត្តិផ្សេងៗ ដើម្បីស្វែងយល់ថា តើស្ត្រីដែលមានលក្ខណៈសម្បត្តិខុសៗគ្នា គាត់មានចំណាប់អារម្មណ៍ខុសគ្នាលើបញ្ហាមួយចំនួនដែរ ឬយ៉ាងណា?

## ការសិក្សា៖ វិធីសាស្ត្រ និងទិន្នន័យ

អង្កេតបានធ្វើឡើងពីខែតុលា ២០១៧ ដល់ មករា ២០១៨ ដោយមានការធ្វើសម្ភាសន៍ជាមួយពលរដ្ឋកម្ពុជាចំនួន ១.៦០០នាក់ក្នុង ១០១ភូមិ (៧២% នៅជនបទ និង ២៩% នៅទីក្រុង) ក្នុងខេត្តចំនួន ៥ (កំពត បាត់ដំបង ស្ទឹងត្រែង ស្វាយរៀង កំពង់ចាម) និងរាជធានីភ្នំពេញ។ ក្នុងក្របខ័ណ្ឌសំណាក មានអ្នកឆ្លើយសម្ភាសន៍ ៩៥៧នាក់ជាស្ត្រី និង ៦៤៣នាក់ជាបុរស ដែលចែកចេញជាពីរក្រុមគឺ ជនវ័យក្មេងឬយុវជន (អាយុ ១៦-៣០ឆ្នាំ) និង មនុស្សជំនាន់មុន (អាយុលើស ៣០ឆ្នាំ) ដូច្នេះក្នុងសំណាកសរុបមាន ២៤,៩% ជាយុវជន និង ៧៥,១% ជាមនុស្សជំនាន់មុន ។ កម្រងសំណួរអង្កេត មាន ១០១សំណួរចែកចេញជា ៦ផ្នែក ដែលជាប់ទាក់ទងនឹង ប្រជាសាស្ត្រ អត្តសញ្ញាណ និងសីលធម៌ ទំនុកចិត្តនិងការគោរព ការរំពឹងទុកទៅអនាគត ការចូលរួមផ្នែកនយោបាយ និង ប្រព័ន្ធផ្សព្វផ្សាយ។

ការវិភាគយេនឌ័រ (Un, Saphon and Sok 2019) បានយកចម្លើយក្នុងអង្កេត មកធ្វើជាប្រភពទិន្នន័យចម្បងតែមួយគត់ ដោយបែងចែកតាមប្រធានបទធំៗចំនួនបួន៖ គ្រួសារ ឥរិយាបថចំពោះសហគមន៍ ចំណេះដឹងនិងឥរិយាបថផ្នែកនយោបាយ និងការរំពឹងទុកទៅអនាគត។ ចម្លើយតាមប្រធានបទនីមួយៗបានយកមកផ្តុំតាមប្រធានបទតូចៗជាច្រើន និងដាក់លេខកូដតាមលក្ខណៈសម្បត្តិ ៧យ៉ាង (តារាង ១ និង ២)។

---

អត្ថបទនេះរៀបរៀងដោយ បណ្ឌិត អ៊ុន លាង ព្រឹទ្ធបុរស មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រ សោម៉ូលីរស្មី សោភ័ណ អ្នកសម្របសម្រួលកម្មវិធី បរិញ្ញាប័ត្រជាន់ខ្ពស់ ខាងទស្សនវិជ្ជា និង សុខ សេរី អនុប្រធានការិយាល័យស្រាវជ្រាវ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ សូមយោងអត្ថបទនេះថា៖ UN Leang, Somolireasmey Saphon and Serey Sok . 2019. “Gender Analysis of Survey on Cambodia’s Young and Older Generation: Family, Community, Political Knowledge and Attitudes, and Future Expectations.” *Cambodia Development Review* 22 (4): 10-14. Phnom Penh: CDRI.

តារាង១៖ ប្រធានបទចម្បងៗ និងប្រធានបទតូចៗ

| ប្រធានបទចម្បងៗ | ប្រធានបទតូចៗ |
|---|---|
| គ្រួសារ | គម្លាតរវាងជំនាន់មនុស្ស<br>ការធ្វើសេចក្ដីសម្រេចចិត្តក្នុងគ្រួសារ<br>ការធ្វើសេចក្ដីសម្រេចចិត្តអំពីការរៀបការ |
| ឥរិយាបថចំពោះសហគមន៍ | ទំនុកចិត្តផ្នែកសង្គមនិងស្ថាប័ន<br>ការគិតគូរពីប្រទេសជាតិ<br>ការចូលរួមក្នុងសហគមន៍ |
| ចំណេះដឹង និងឥរិយាបថផ្នែកនយោបាយ | ការយល់ឃើញផ្នែកយេនឌ័រលើភាពជាអ្នកដឹកនាំ<br>ការចូលរួមផ្នែកសង្គមនិងនយោបាយ<br>ការបារម្ភពីបញ្ហា និងសេវាផ្នែកសង្គម |
| ការរំពឹងទុកទៅអនាគត | ទិសដៅរបស់ប្រទេសជាតិ<br>ការរំពឹងទុកផ្ទាល់ខ្លួន |

តារាង២៖ ការដាក់លេខកូដទិន្នន័យ

| លក្ខណសម្បត្តិ | រង្វាស់ |
|---|---|
| អាយុ | យុវជនឬជនវ័យក្មេង (អាយុ ១៦-៣០ឆ្នាំ)<br>មនុស្សជំនាន់មុន (អាយុលើស ៣០ឆ្នាំ) |
| កន្លែងរស់នៅ | រាជធានីភ្នំពេញ<br>មិនមែនរាជធានីភ្នំពេញ |
| កម្រិតអប់រំសម្រេចបាន * | ការអប់រំកម្រិតមូលដ្ឋានឬទាបជាង<br>ការអប់រំខ្ពស់ជាងកម្រិតមូលដ្ឋាន |
| ស្ថានភាពរៀបការ | នៅលីវ<br>មិនមែននៅលីវ (រៀបការរួច, រួមរស់ជាមួយគ្នា) |
| ប្រភេទការងារ | ការងារមានប្រាក់ឈ្នួល<br>ការងារគ្មានប្រាក់ឈ្នួល |
| ភាពចល័ត | ពលករចំណាកស្រុក<br>មិនមែនពលករចំណាកស្រុក |
| លទ្ធភាពប្រើប្រាស់អ៊ិនធើណិត | អ្នកប្រើប្រាស់អ៊ិនធើណិត<br>មិនមែនអ្នកប្រើប្រាស់អ៊ិនធើណិត |

កំណត់សំគាល់៖ *បានជ្រើសរើសយកប្រភេទទាំងនេះ ព្រោះរដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ថា ការអប់រំកម្រិតមូលដ្ឋាន គឺ ការបានចូលរៀនក្នុងសាលាយ៉ាងហោចណាស់ ៩ឆ្នាំ ប៉ុន្តែជាមធ្យម(mean)ការចូលរៀនក្នុងសាលានៅកម្ពុជាមានកម្រិតទាបត្រឹម ៤,៨ឆ្នាំ នៅឆ្នាំ២០១៧ (hdr.undp.org/sites/all/them es/hdr_theme/country-notes/KHM.pdf).

ការផ្ទុផ្ទងទិន្នន័យលើលក្ខណសម្បត្តិទាំង ៧ ដែលបានជ្រើសយក បានផ្ដល់នូវតារាងច្រើនណាស់ ដូច្នេះអ្នកស្រាវជ្រាវបានប្រើលក្ខណវិនិច្ឆ័យដូចខាងក្រោម ដើម្បីស្វែងរកលទ្ធផលសំខាន់ៗ៖

- សំណួរអង្កេតជាប់ពាក់ព័ន្ធល្អនឹងប្រធានបទទាំងបួនដែលបានជ្រើសយកសម្រាប់ការសិក្សា
- ភាពខុសគ្នាជាភាគរយ រវាងចម្លើយនានាលើលក្ខណសម្បត្តិនីមួយៗ។ ភាពខុសគ្នាត្រូវបានបញ្ជាក់តាមស្ថិតិ (បើសិនមានទិន្នន័យ) បើពុំនោះទេ ភាពខុសគ្នា ១០% ត្រូវបានយកមកប្រើជាកម្រិតគោល
- សំណួរដដែលឬស្រដៀងគ្នាត្រូវបាន ស្ថាប័នរដ្ឋ អ្នកស្រាវជ្រាវអង្កេតសម្រាប់ការស្រាវជ្រាវ និងការសិក្សានានា លើកមកពិភាក្សា និងផ្ដល់អាទិភាព។

## លទ្ធផលរកឃើញ

លទ្ធផលបង្ហាញថា លក្ខណសម្បត្តិនានាដែលបានជ្រើសយកមកវិភាគ ធ្វើឲ្យគេមានអារម្មណ៍ថា ស្ត្រីជាមនុស្សមានប្រភេទខុសៗគ្នា ហើយលក្ខណសម្បត្តិទាំងនេះជះឥទ្ធិពលខ្លាំងដល់ការចូលរួម និងការយល់ដឹងផ្នែកសង្គម និងផ្នែកនយោបាយរបស់ស្ត្រី។ លទ្ធផលរកឃើញនេះ មានការពាក់ព័ន្ធសំខាន់សម្រាប់គោលនយោបាយ និងរបៀបរបបអនុវត្តផ្នែកយេនឌ័រ ក៏ដូចជាការស្រាវជ្រាវទៅអនាគត ពីព្រោះការព្យាយាមផ្ដល់សិទ្ធិអំណាច និងលើកកម្ពស់សមភាពនិងសមធម៌ផ្នែកយេនឌ័រដល់ស្ត្រី ដោយចាត់ទុកស្ត្រីជាមនុស្សមួយក្រុមដូចគ្នាទាំងអស់នោះ ទំនងមិនអាចបានផលដូចការរំពឹងទុកឡើយ។

### *គ្រួសារ*

*គម្លាតរវាងជំនាន់មនុស្ស៖* ការប្រែប្រួលផ្នែកប្រជាសាស្ត្រ ដោយសារការស្ទុះឡើងជាខ្លាំងនៃកំណើតទារក (baby boom) ក្រោយពេលរបបខ្មែរក្រហមបានដួលរលំ គួបផ្សំនឹង ការល្អប្រសើរឡើងក្នុងការអប់រំ ក្នុងលទ្ធភាពបានប្រើប្រព័ន្ធផ្សព្វផ្សាយ ក្នុងរបៀបរស់នៅមានវប្បធម៌ចម្រុះនៅទីក្រុង គឺបាននាំឲ្យមានគម្លាតរវាងជំនាន់មនុស្ស។ ក្នុងនេះអ្នកឆ្លើយសម្ភាសន៍ភាគច្រើនបានទទួលស្គាល់ថា ជំនាន់គាត់ខុសប្លែកជាខ្លាំងពីជំនាន់ផ្សេងទៀត និងមានតែជាង ៥០% បន្តិចប៉ុណ្ណោះដែលយល់ស្របថា គេអាចទទួលយកបាន បើសិនយុវជនមិនឯកភាពជាមួយឪពុកម្ដាយ។ សម្រាប់អ្នកឆ្លើយសម្ភាសន៍ជាស្ត្រី គេរកឃើញថា អ្នករស់នៅរាជធានីភ្នំពេញ អ្នកមានការសិក្សាអប់រំខ្ពស់ជាងកម្រិតមូលដ្ឋាន និងអ្នកប្រើអ៊ិនធើណិត តែងមានចំណាប់អារម្មណ៍ខុសប្លែកពីគេ។

*ការធ្វើសេចក្ដីសម្រេចចិត្តក្នុងគ្រួសារ៖* គម្លាតរវាងជំនាន់មនុស្សមិនគ្រាន់តែប៉ះពាល់ដល់បញ្ហាថា អ្នកណាត្រូវធ្វើសេចក្ដីសម្រេចចិត្តនោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់ បញ្ហាអ្វីត្រូវធ្វើសេចក្ដីសម្រេចចិត្ត និងហេតុអ្វីត្រូវធ្វើសេចក្ដីសម្រេចចិត្ត ផងដែរ។ ថ្វីបើឪពុកម្ដាយនៅតែមានភារកិច្ចធ្វើការសម្រេចចិត្ត ប៉ុន្តែយុវជនកាន់តែមានអារម្មណ៍ថា ខ្លួនឯងគួរមានទំនួលខុសត្រូវធ្វើការសម្រេចចិត្តលើដំណើរជីវិតរបស់ខ្លួន ដូចជាលើ ការអប់រំ ការងារ និង ការរៀបការ ជាដើម។ ឧទាហរណ៍ ឪពុកម្ដាយនៅតែសម្រេចអារកាត់ច្រើនលើការអប់រំ ប៉ុន្តែតែងបានចូលរួមសម្រេចចិត្តតិចជាងក្នុងការជ្រើសរើសការងារសម្រាប់កូន។ សម្រាប់អ្នកឆ្លើយសម្ភាសន៍ជាស្ត្រី គេបានពិនិត្យឃើញនូវ ចំនួនភាគរយយ៉ាងខ្ពស់នៃអ្នករស់នៅរាជធានីភ្នំពេញ អ្នកមានការអប់រំខ្ពស់ជាងកម្រិតមូលដ្ឋាន និង អ្នកប្រើអ៊ិនធើណិត ដែលយល់ថា យុវជនគួរមានសិទ្ធិអំណាចធ្វើការសម្រេចចិត្តដោយខ្លួនឯង។

*ការរៀបការ៖* សង្គមកម្ពុជាឲ្យតម្លៃខ្ពស់ដល់មង្គលការ ព្រោះវាជាជំហានគេអាចទទួលយកបាន និងគោរពទទួលស្គាល់ ដើម្បីកសាងគ្រួសារ និងក្លាយជាឪពុកម្ដាយគេ។ ការរួមរស់ជាមួយគ្នាមុនពេលរៀបការ ពុំមានការឲ្យតម្លៃ ឬទទួលយកពីមហាជនទេ។ ជាក់ស្ដែង ប្រមាណ ៨០% នៃស្ត្រីឆ្លើយសម្ភាសន៍បាននិយាយថា

គូគ្រងមិនគួររួមរស់ជាមួយគ្នា មុនពេលរៀបការទេ ហើយសឹងគ្រប់គ្នាយល់ថា មង្គលការ និងការកសាងគ្រួសារមានសារៈសំខាន់ខ្លាំង ចំណែកឯ អ្នកឆ្លើយសម្ភាសន៍ជាងពាក់កណ្តាល យល់ថា មង្គលការ និងការកសាងគ្រួសារមានសារៈសំខាន់ក្រៃលែង។ យ៉ាងនេះមិនមែនមានន័យថា គ្មានស្ត្រីជំទាស់នឹងទំនៀមទម្លាប់ប្រពៃណីនោះទេ ព្រោះមានស្ត្រីខ្លះឆ្លើយសម្ភាសន៍យល់ស្របនឹងការរួមរស់ជាមួយគ្នាមុនពេលរៀបការ ក្នុងនេះ មាន អ្នករស់នៅរាជធានីភ្នំពេញ ១៨,៧% អ្នកមិនរស់នៅរាជធានីភ្នំពេញ ១១,៥% ស្ត្រីវ័យចំណាស់ ១៣,៨% និង ស្ត្រីវ័យក្មេង ៩,៨% ។

## ឥរិយាបថចំពោះសហគមន៍

*ទំនុកចិត្តលើសង្គមៈ* ទំនុកចិត្តលើសង្គម មានសារៈសំខាន់ដល់សេដ្ឋកិច្ចសង្គមរបស់ប្រទេសជាតិ (ឧទាហរណ៍ កំណើនសេដ្ឋកិច្ច និងការពេញចិត្តនឹងជីវភាពរស់នៅ) គឺដូចគ្នានឹងវិនិយោគលើទ្រព្យមូលធន ហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍជំនាញដែរ។ អង្កេតវាស់វែងបរិយាកាសអាស៊ី(Asia Barometer Survey)ឆ្នាំ២០០៣-០៦ ក្នុង ២៩ប្រទេស បង្ហាញថា កម្ពុជាមានទំនុកចិត្តលើសង្គមកម្រិតទាបជាងគេ (Tokuda, Fujii and Inoguch 2010) ដែលអាចបណ្តាលមកពី សង្គ្រាមអូសបន្លាយជិតបីទសវត្សរ៍ របបគ្រប់គ្រងផ្តាច់ការខ្មែរក្រហម (Zucker 2013; Scheer 2017) និងផលប៉ះពាល់ពីការផ្តល់សេវាដែលមានអំពើពុករលួយ ក្នុងអំឡុងនៃការកសាងប្រទេសឡើងវិញក្រោយបញ្ចប់សង្គ្រាម (Baker and Milne 2019)។ ប៉ុន្តែគួរឲ្យរីករាយណាស់ដែល លទ្ធផលអង្កេតចុះក្នុង តារាង ៣ បង្ហាញថា ប្រជាជនមានទំនុកចិត្តខ្ពស់បង្គួរ ឬខ្ពស់ ទៅលើសាលារៀន មន្ទីរពេទ្យ ស្ថាប័នក្នុងមូលដ្ឋាន ប្រព័ន្ធផ្សព្វផ្សាយ ប៉ូលីសនិងតុលាការ និង អ្នកនយោបាយ ទោះបីក្នុងកម្រិតខុសៗគ្នាក្តី។ គួរកត់សំគាល់ថា មានអ្នកឆ្លើយសម្ភាសន៍តិចនាក់ណាស់ដែលជ្រើសយកប្រយោគថា "ខ្ញុំមិនទុកចិត្តស្ថាប័ន ឬជនណាមួយទេ" ។

តារាង៣៖ តើអ្នកទុកចិត្តលើស្ថាប័នណា ឬអ្នកណាខ្លាំងជាងគេ (%) (N=1600)

| | បុរស | ស្ត្រី |
|---|---|---|
| មន្ទីរពេទ្យ/សាលារៀន | 89.4 | 92.3 |
| ស្ថាប័នក្នុងមូលដ្ឋាន | 87.5 | 88.7 |
| ប្រព័ន្ធផ្សព្វផ្សាយ | 77.5 | 75.6 |
| ប៉ូលីស/តុលាការ | 71.4 | 78.3 |
| អ្នកនយោបាយ | 65.7 | 65.6 |
| ខ្ញុំមិនទុកចិត្តលើ ស្ថាប័ន/អ្នកណាទេ | 3.8 | 2.8 |

ទោះបីមានជោគជ័យគួរឲ្យសរសើរក្តី កម្ពុជានៅតែជាប្រទេសកំពុងអភិវឌ្ឍ និងពឹងផ្អែកលើជំនួយគាំទ្រពីស្ថាប័នសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍អន្តរជាតិនានា។ ប៉ុន្តែដូចអ្នកសង្កេតការណ៍ជាច្រើននាក់បានលើកឡើងដែរ វត្តមានស្ថាប័នទាំងនេះមិនមែនគ្មានបញ្ហាចោទអ្វីសោះនោះទេ (Domashneva 2013)។ មានស្ត្រីអ្នកឆ្លើយសម្ភាសន៍តិចនាក់ណាស់ ក្នុងនោះមានទាំងអ្នកមានការអប់រំកម្រិតខ្ពស់ និងអ្នករស់នៅរាជធានីភ្នំពេញផង ដែលមានអារម្មណ៍ថា អាចទុកចិត្តទាំងស្រុងទៅលើអ្នកធ្វើការផ្នែកអភិវឌ្ឍន៍នៅក្នុងសហគមន៍របស់ខ្លួន។ គួរកត់សំគាល់ថា មានស្ត្រីច្រើននាក់និយាយថា គាត់ "ទុកចិត្តខ្លះ/មិនទុកចិត្តខ្លះ" លើអ្នកធ្វើការផ្នែកអភិវឌ្ឍន៍។ បញ្ហានេះជាក្តីបារម្ភមួយ ព្រោះកម្ពុជាមានចំនួន NGOs សកម្មគិតក្នុងមនុស្សម្នាក់ ច្រើនជាងគេលំដាប់ទី២ ក្នុងពិភពលោក (Domashneva 2013)។

*ការគិតគូរពីប្រទេសជាតិ និងការចូលរួមក្នុងសហគមន៍៖* ជាងពាក់កណ្តាលនៃស្ត្រីអ្នកឆ្លើយសម្ភាសន៍និយាយថា គាត់គិតគូរពីសហគមន៍គាត់ និងប្រទេសជាតិ។ ការវិភាគតាមលក្ខណសម្បត្តិផ្សេងៗបង្ហាញថា ក្នុងចំណោមអ្នកនិយាយថា ខ្លួនគិតគូរពីប្រទេសជាតិ ស្ត្រីវ័យចំណាស់ (៥៩,៣%) មានច្រើនជាងស្ត្រីវ័យក្មេង (៤៨,៦%) ហើយ អ្នករស់នៅតំបន់ជនបទ (៥៨,៤%) មានច្រើនជាងអ្នករស់នៅរាជធានីភ្នំពេញ (៤៧,៦%)។ ប៉ុន្តែការគិតគូរនេះ មិនមែនសុទ្ធតែស្តែងចេញជាការចូលរួមសកម្មក្នុងសហគមន៍ឬសង្គមនោះទេ ជាពិសេស ក្នុងចំណោមស្ត្រីអ្នកឆ្លើយសម្ភាសន៍រស់នៅក្រុងភ្នំពេញ អ្នកមានការអប់រំខ្ពស់ជាងកម្រិតមូលដ្ឋាន និងអ្នកមិនប្រើអ៊ីនធើណិត។ តាមពិត ការចូលរួមមានលក្ខណៈអកម្មភាគច្រើន។ ជាក់ស្តែង ស្ត្រីភាគច្រើនដែលបានចូលរួមក្នុងព្រឹត្តិការណ៍ផ្សេងៗនៅតាមមូលដ្ឋាន មិនបាននិយាយ ឬលើកសំណួរអ្វីទេ ទោះបីគាត់អះអាងថា គាត់មិនខ្លាចបញ្ចេញមតិ ឬលើកសំណួរក្តី។

## ចំណេះដឹង និងឥរិយាបថផ្នែកនយោបាយ

*ការយល់ឃើញផ្នែកយេនឌ័រលើភាពជាអ្នកដឹកនាំ៖* ក្នុងសង្គមកម្ពុជា មានការលើកកម្ពស់សិទ្ធិអំណាចស្ត្រីជាខ្លាំង និងមានការផ្លាស់ប្តូរអាកប្បកិរិយាគួរឲ្យកត់សំគាល់ ប៉ុន្តែផ្នត់គំនិត និងរបៀបរបបនិងឥរិយាបថក្នុងសង្គម នៅតែជាឧបសគ្គរារាំងដល់ស្ត្រី ហើយស្ត្រីនៅតែមានអ្នកតំណាងតិច ជាពិសេស អ្នកតំណាងមានតួនាទីសម្រេចអាកាត់។ ទម្លាប់ផ្តល់តម្លៃខ្ពស់ឲ្យទៅបុរសនៅតែចាក់ឫសយ៉ាងរឹងមាំក្នុងសង្គមកម្ពុជា ហើយអ្នកឆ្លើយសម្ភាសន៍ទាំងបុរសទាំងស្ត្រី សុទ្ធតែគោរពតាមទម្លាប់នេះដោយគិតថា វាជារបៀបរបប និងឥរិយាបថពាក់ព័ន្ធនឹងបុព្វសិទ្ធិផ្នែកយេនឌ័រ។ ក្នុងនេះបញ្ហាប្រឈមពិបាកដោះស្រាយជាងគេ អាចមិនមែនជាការរើសអើងប្រឆាំងនឹងស្ត្រីនោះទេ ប៉ុន្តែដោយសារតែ ស្ត្រីសុខចិត្តទទួលយកផ្នត់គំនិតក្នុងសង្គម ដែលចាត់ទុកខ្លួនដូចជាវត្ថុមួយបែប (Saphon 2015)។ មានអ្នកឆ្លើយសម្ភាសន៍ជាស្ត្រី ច្រើនជាងជាបុរស ដែលយល់ស្របថា បុរសធ្វើជាអ្នកដឹកនាំនយោបាយបានល្អជាងស្ត្រី និងមានច្រើននាក់ជាងដែរ ជាពិសេសក្នុងចំណោមអ្នកមានអាយុជាង ៣០ឆ្នាំ និងអ្នកមានការអប់រំកម្រិតមូលដ្ឋានឬទាបជាង ដែលបង្ហាញថា គាត់ភ័យខ្លាចនឹងពិភាក្សាដោយចំហពីការយល់ឃើញផ្នែកនយោបាយ។

*ភាពលំអៀងផ្នែកយេនឌ័រក្នុងការអប់រំ៖* តាមអង្កេតរបស់ CDRI (Eng at al. 2019) ៧៥% នៃអ្នកឆ្លើយសម្ភាសន៍យល់ថា ស្ត្រី និងបុរស គួរមានឱកាសស្មើគ្នាដើម្បីទទួលបានការអប់រំកម្រិតឧត្តមសិក្សា និងមានប្រមាណ ៩០% ឲ្យតម្លៃខ្ពស់ដល់អ្នករៀនចប់ឧត្តមសិក្សា។ ប៉ុន្តែភាពលំអៀងផ្នែកយេនឌ័រនៅតែមាន ព្រោះមានស្ត្រីអ្នកឆ្លើយសម្ភាសន៍ច្រើននាក់ដែរដែលយល់ស្របថា ក្មេងប្រុស ប្រសើរជាងក្មេងស្រីសម្រាប់ការសិក្សានៅសាកលវិទ្យាល័យ ហើយគំនិតនេះឃើញមានច្រើនជាងគេក្នុងចំណោមស្ត្រីអាយុជាង ៣០ឆ្នាំ (៣០,៣%), អ្នកមិនរស់នៅក្នុងក្រុងភ្នំពេញ (២៨,១%) និង អ្នកមានប្តីឬមានដៃគូរួមរស់ជាមួយ (២៨,១%) ។

*ការចូលរួមក្នុងការបោះឆ្នោត៖* អ្នកឆ្លើយសម្ភាសន៍ភាគច្រើន ជាពិសេសអ្នកប្រើអ៊ីនធើណិត បានប្រើសិទ្ធិបោះឆ្នោតរបស់ខ្លួន។ មនុស្សជំនាន់មុនសឹងគ្រប់គ្នា (បុរស ៩៤,៣% ស្ត្រី ៩២,៤%) បានបោះឆ្នោត ក្នុងពេលបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ឆ្នាំ ២០១៣ ធៀបនឹង ជនពេញវ័យនៅក្មេងមិនដល់ ៥០% ទេ ដែលបានទៅបោះឆ្នោត (បុរស ៤៣,១% ស្ត្រី ៤៤,១%)។ ក្នុងចំណោមអ្នកទៅបោះឆ្នោត មាន ៧១,៥% ជាអ្នកប្រើអ៊ីនធើណិត។ ការទៅបោះឆ្នោតច្រើនបែបនេះ បង្ហាញថា ប្រជាជនកម្ពុជាឲ្យតម្លៃដល់សិទ្ធិបោះឆ្នោតរបស់ខ្លួន ដោយយល់ឃើញថា វាជាទំនួលខុសត្រូវដ៏សំខាន់ និងជាកត្តាសំខាន់សម្រាប់របបប្រជាធិបតេយ្យ ហើយសន្លឹកឆ្នោតរបស់ខ្លួនមានប្រយោជន៍សម្រាប់ប្រទេសជាតិ។

*ចេតនាបោះឆ្នោត៖* មានអ្នកបោះឆ្នោតជាស្ត្រី (២៥,០%) ច្រើនជាងជាបុរស (១៦,៧%) និងមានស្ត្រីអាយុលើស ៣០ឆ្នាំ (៤១,៦%) ច្រើនជាខ្លាំងជាងស្ត្រីអាយុ ១៦-៣០ឆ្នាំ (២៣,៧%) ដែលបោះឆ្នោតឲ្យគណបក្សនយោបាយដដែលរហូត ក្នុងការបោះឆ្នោតថ្នាក់ជាតិ។ ចេតនានេះស៊ីគ្នានឹង បែបបទដែលអ្នកឆ្លើយសម្ភាសន៍ភាគច្រើនបោះឆ្នោត ពោលគឺ ដោយផ្អែកលើគណបក្សនយោបាយជាជាងលើគុណសម្បត្តិ ឬឥទ្ធិពលផ្សេងៗរបស់បេក្ខជន។

*ក្តីបារម្ភពីបញ្ហា និងសេវាសង្គម៖* ក្នុងចំណោមបញ្ហា និងសេវាសង្គមជាតិទាំង ១៤មុខ (ហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ សុខាភិបាល សេដ្ឋកិច្ចនិងការងារ បរិស្ថាន ភាពក្រីក្រ ភាពគ្មានដីធ្លីនិងការជំពាក់បំណុល អំពើល្មើសច្បាប់និងបញ្ហាសន្តិសុខ អំពើពុករលួយ ទំនាស់រវាងគណបក្សនយោបាយ អំពើអយុត្តិធម៌ បញ្ហាព្រំដែន វិសមភាពទ្រព្យធនកាន់តែធំឡើងរវាងអ្នកក្រនឹងអ្នកមាន និង ចំណាកស្រុក) អ្នកឆ្លើយសម្ភាសន៍ទាំងស្ត្រីទាំងបុរស បានធ្វើចំណាត់ថ្នាក់ ហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ សុខាភិបាល សេដ្ឋកិច្ច និងការងារ និង បរិស្ថាន ជាបញ្ហាសំខាន់ៗជាងគេដែលរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ជាបន្ទាន់។

## ក្តីរំពឹងទៅអនាគត

*ទិសដៅប្រទេសជាតិកំពុងប្រកាន់យក៖* អ្នកឆ្លើយសម្ភាសន៍ភាគច្រើនយល់ថា ប្រទេសជាតិកំពុងស្ថិតលើផ្លូវត្រូវ ដោយយោងជាសំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ក្នុងចំណោមស្ត្រីអ្នកឆ្លើយសម្ភាសន៍ដែលយល់បែបនេះ មាន ៥៩,៧% នៃអ្នកមានការអប់រំខ្ពស់ជាងកម្រិតមូលដ្ឋាន និង ៧២,០% នៃអ្នកមានការអប់រំកម្រិតមូលដ្ឋានឬទាបជាង។ ចំណុចលេចធ្លោមួយគឺ ភាពខុសប្លែកគ្នាដោយសារការប្រើអ៊ីនធើណិត។ ក្នុងចំណោមស្ត្រីអ្នកឆ្លើយសម្ភាសន៍ អ្នកយល់ឃើញថាប្រទេសជាតិកំពុងស្ថិតលើផ្លូវត្រូវមានតែ ១៦,៧% នៃអ្នកមិនប្រើអ៊ីនធើណិត ធៀបនឹង ៥៩,០% នៃអ្នកប្រើអ៊ីនធើណិត។

*ការរំពឹងទុកទៅអនាគតរបស់បុគ្គល៖* មានស្ត្រីអ្នកឆ្លើយសម្ភាសន៍ក្នុងចំនួនភាគរយខ្ពស់គួរឲ្យកត់សំគាល់ ដែលបារម្ភថា ផ្នត់គំនិតផ្នែកយេនឌ័រ ជាឧបសគ្គរារាំងដល់ជោគជ័យក្នុងអាជីពរបស់ខ្លួន។ ជាក់ស្តែង ក្នុងចំណោមស្ត្រីអ្នកឆ្លើយសម្ភាសន៍ គឺក្រុមស្ត្រីវ័យចំណាស់ អ្នកមិនរស់នៅក្នុងក្រុងភ្នំពេញ និងអ្នកមានការអប់រំកម្រិតមូលដ្ឋានឬទាបជាង តែងគិតឃើញធ្ងន់ធ្ងរជាង ស្ត្រីវ័យក្មេង និងអ្នកមានការអប់រំខ្ពស់ជាងកម្រិតមូលដ្ឋាន ថា ផ្នត់គំនិតផ្នែកយេនឌ័រជាឧបសគ្គរារាំងដល់ជោគជ័យរបស់ខ្លួន។

## សេចក្តីសន្និដ្ឋាន

កម្ពុជា នៅមាន ចំណុចជាច្រើនដែលអាចកែលំអថែមទៀត ក្នុងការផ្តល់សិទ្ធិអំណាចឲ្យស្ត្រី និង ក្នុងសមភាពផ្នែកយេនឌ័រ ទោះបីជា ទិដ្ឋភាពជាច្រើននៃជីវិតរស់នៅជាក់ស្តែងរបស់ស្ត្រីបានល្អប្រសើរឡើងគួរឲ្យកត់សំគាល់ក្តី។ ការល្អប្រសើរនេះមិនមែនសម្រាប់តែស្ត្រីខ្លួនឯងនោះទេ ប៉ុន្តែក៏សម្រាប់ការចូលរួមក្នុងសង្គមផងដែរ។ រហូតមកដល់ពេលថ្មីៗនេះ ការសិក្សាវិភាគពីយេនឌ័រនានា បានប្រៀបធៀបស្ថានភាពស្ត្រីពីមួយឆ្នាំទៅមួយឆ្នាំ និងបានប្រៀបធៀបជាមួយស្ថានភាពរបស់បុរស ហើយជាទូទៅតែងចាត់ទុកស្ត្រីជាមនុស្សមួយក្រុមដូចគ្នាទាំងអស់។ លទ្ធផលរកឃើញបង្ហាញថា លក្ខណៈ និងបទពិសោធន៍ខុសប្លែកគ្នាជះឥទ្ធិពលទៅលើចំណាប់អារម្មណ៍ និងការចូលរួមរបស់ស្ត្រីក្នុងបញ្ហាសង្គម-នយោបាយផ្សេងៗ។ ដូច្នេះ ការព្យាយាមណាមួយដើម្បីផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងលើកកម្ពស់សមភាព និងសមធម៌យេនឌ័រ ប៉ុន្តែដោយចាត់ទុកស្ត្រីជាមនុស្សមួយក្រុមដូចគ្នាទាំងអស់ គឺពិតជាមិនអាចបានផលដូចការរំពឹងទុកទេ។

សម្រាប់លក្ខណៈសម្បត្តិទាំង ៧ ដែលបានជ្រើសរើសសម្រាប់ការសិក្សា ក្រុមស្រាវជ្រាវសន្និដ្ឋានថា កត្តា អាយុ កន្លែងស្នាក់នៅ កម្រិតអប់រំ និង ការប្រើអ៊ីនធើណិត មានឥទ្ធិពលគួរឲ្យកត់សំគាល់ទៅលើ ចំណាប់អារម្មណ៍ និងការចូលរួមរបស់ស្ត្រីក្នុងសង្គម-នយោបាយ។ ខាងក្រោមនេះ ជាសេចក្តីសង្ខេបនៃលទ្ធផលរកឃើញ និងបញ្ហាកំពុងផុសឡើង ដែលគួរទទួលបានការយកចិត្តទុកដាក់ខ្លាំងថែមទៀត ពីបណ្តាស្ថាប័នមានបេសកកម្មលើកកម្ពស់ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងសមភាព និងសមធម៌ផ្នែកយេនឌ័រ។

- គ្រួសារ
  - ជនវ័យក្មេង កាន់តែត្រូវបានអនុញ្ញាតឲ្យទទួលខុសត្រូវធ្វើការសម្រេចចិត្តលើដំណើរជីវិតរបស់ខ្លួន។ *ស្ត្រីវ័យក្មេង ជាអ្នកមានការអប់រំខ្ពស់ជាងកម្រិតមូលដ្ឋាន ជាអ្នករស់នៅ*

*រាជធានីភ្នំពេញ និងជាអ្នកប្រើអ៊ិនធើណិត ទំនងមានការយល់ស្របតិច ជាមួយ ប្រពៃណីក្នុងសង្គមកម្ពុជា និងរបៀបរបបរស់នៅ និងការគិតគូរបែបអភិរក្ស បើធៀបនឹង ស្ត្រីវ័យក្មេងមានការអប់រំកម្រិតមូលដ្ឋាន ឬទាបជាង ស្ត្រីរស់នៅរាជធានីភ្នំពេញ និងស្ត្រីមិនប្រើអ៊ិនធើណិត។*

- ឥរិយាបថចំពោះសហគមន៍
    - បញ្ហាទំនុកចិត្តរបស់ប្រជាពលរដ្ឋទៅលើស្ថាប័នជាតិ និងមន្ត្រីរាជការ អាចឡើងដល់កម្រិតមុនពេលមានសង្គ្រាម ឬយ៉ាងណា គេមិនទាន់ដឹងនៅឡើយទេ ប៉ុន្តែលទ្ធផលអង្កេតបានបង្ហាញសញ្ញាវិជ្ជមានខ្លះ។ ប្រជាជនយល់ថា មន្ទីរពេទ្យ សាលារៀន ជាស្ថាប័នគួរឲ្យទុកចិត្តជាងគេ រីឯស្ថាប័នក្នុងមូលដ្ឋាន ប្រព័ន្ធផ្សព្វផ្សាយ ប៉ូលីស/តុលាការ និង អ្នកនយោបាយ គឺអាចទុកចិត្តបានបង្គួរ។ ចំណុចសំខាន់គួរកត់សំគាល់ គឺមាន *អ្នកឆ្លើយសម្ភាសន៍តិចនាក់ណាស់ដែលបញ្ជាក់ថា មិនមានទំនុកចិត្តលើស្ថាប័នឬជនណាមួយដូចខាងលើ។*
    - ប្រមាណជិតពាក់កណ្ដាលនៃ ស្ត្រីអ្នកឆ្លើយសម្ភាសន៍ទុកចិត្តខ្លះ មិនទុកចិត្តខ្លះ ទៅលើអ្នកធ្វើការផ្នែកអភិវឌ្ឍន៍។ *ចំណុចនេះគួរឲ្យបារម្ភដែរ ព្រោះនៅកម្ពុជា មានចំនួន NGOs សកម្មគិតក្នុងមនុស្សម្នាក់ ច្រើនជាងគេលំដាប់ទី២ ក្នុងពិភពលោក។*
    - ស្ត្រីអ្នកឆ្លើយសម្ភាសន៍ភាគច្រើន ឬមួយគិតគូរ ឬមួយគិតគូរខ្លះមិនគិតគូរខ្លះ ពីប្រទេសជាតិខ្លួន ហើយការគិតគូរនេះឃើញមានច្រើនជាងគេក្នុងចំណោម ស្ត្រីវ័យចំណាស់ (ធៀបនឹងស្ត្រីវ័យក្មេង) និងអ្នកមិនរស់នៅរាជធានីភ្នំពេញ (ធៀបនឹងអ្នករស់នៅរាជធានីភ្នំពេញ)។ ចំណុចនេះគួរយកចិត្តទុកដាក់ដែរ *ព្រោះនៅកម្ពុជា យុវជនតំណាងឲ្យប្រមាណ ៦០% នៃប្រជាជនសរុប ហើយនគរូបនីយកម្មមានល្បឿនយ៉ាងលឿន។*
    - ការគិតគូរពីប្រទេសជាតិ មិនមែនសុទ្ធតែស្ដែងចេញជាការចូលរួមសកម្មក្នុងសហគមន៍នោះទេ។ សូម្បីក្នុងចំណោមអ្នកចូលរួមការប្រជុំក្នុងមូលដ្ឋានដែលអះអាងថា គាត់មិនខ្លាចបញ្ចេញមតិក្នុងពេលចូលរួមក្ដី ក៏ភាគច្រើនមិនដែលមានលើកជាសំណួរអ្វីទេក្នុងពេលចូលរួម។ ការសិក្សាថែមទៀត ដើម្បីពិនិត្យពីការរារែករបស់ប្រជាជនក្នុងការបញ្ចេញមតិនៅពេលប្រជុំជាសាធារណៈ អាចជួយពង្រឹងគុណភាពនៃការចូលរួមបំពេញភារកិច្ចជាពលរដ្ឋ។
- ចំណេះដឹង និងឥរិយាបថផ្នែកនយោបាយ
    - ទោះបីមានកិច្ចប្រឹងប្រែង ដើម្បីផ្ដល់សិទ្ធិអំណាចដល់ស្ត្រី និងលើកកម្ពស់សមភាពយេនឌ័រក្ដី ក៏នៅតែមានការយល់ឃើញថា បុរសធ្វើជាអ្នកដឹកនាំបានល្អជាងស្ត្រី។ ផ្នត់គំនិតនេះនៅតែឃើញមានជាទូទៅ ក្នុងចំណោមស្ត្រី ជាពិសេសស្ត្រីវ័យចំណាស់ ស្ត្រីមានការអប់រំកម្រិតមូលដ្ឋានឬទាបជាង និងស្ត្រីមិនប្រើអ៊ិនធើណិត។ ស្ត្រីមានច្រើនជាងបុរសដែលយល់ថា យេនឌ័រជាឧបសគ្គរាំងជោគជ័យរបស់ខ្លួន ជាពិសេស ស្ត្រីវ័យចំណាស់ អ្នកមិនរស់នៅរាជធានីភ្នំពេញ និងអ្នកមានការអប់រំកម្រិតមូលដ្ឋានឬទាបជាង។ ការដោះស្រាយបញ្ហាសមភាពយេនឌ័រ មិនមែនគ្រាន់តែជាការដោះស្រាយផ្នត់គំនិតរបស់បុរស ស្ដីពី ឋានៈរបស់ស្ត្រីប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការដោះស្រាយចំណាប់អារម្មណ៍របស់ស្ត្រីផ្ទាល់ អំពីតម្លៃ និងតួនាទីរបស់ខ្លួននៅក្នុងសង្គមផងដែរ។ ស្ត្រីមិនគ្រាន់តែទទួលរងការគាបសង្កត់ពីបុរសប៉ុណ្ណោះទេ ប៉ុន្តែក៏មានការគាបសង្កត់ដោយខ្លួនឯងផ្ទាល់ឲ្យនៅជាក្រុមក្រោមបង្គាប់គេ ហើយគំនិតនេះនៅតែជាបញ្ហាស្នូលមួយក្នុងសង្គមកម្ពុជា។
    - អ្នកឆ្លើយសម្ភាសន៍ភាគច្រើន បានប្រើសិទ្ធិបោះឆ្នោតរបស់ខ្លួន និងបានដឹងពីសារៈសំខាន់នៃសន្លឹកឆ្នោតខ្លួនសម្រាប់អនាគតប្រទេសជាតិ។ ពួកគាត់យល់ថា រាជរដ្ឋាភិបាលអាចដោះស្រាយក្ដីបារម្ភរបស់គាត់អំពីសេវា និងបញ្ហាសង្គមជាតិផ្សេងៗ ហើយក្នុងនោះសំខាន់បំផុត គឺហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ សុខាភិបាល សេដ្ឋកិច្ចនិងការងារ និងបរិស្ថាន។
- ការរំពឹងទុកទៅអនាគត
    - អ្នកឆ្លើយសម្ភាសន៍ភាគច្រើនយល់ថា ប្រទេសជាតិកំពុងស្ថិតលើផ្លូវត្រូវ ទោះបីជាមានស្ត្រីអ្នកមិនប្រើអ៊ិនធើណិតតិចនាក់ណាស់ដែលយល់ឃើញដូច្នេះក្ដី។ ចំណុចនេះបង្ហាញពីតម្រូវការបង្កើនចំណេះដឹងពីអ៊ិនធើណិត ព្រមទាំងបំផុសចំណាប់អារម្មណ៍ និងចែករំលែកព័ត៌មាន អំពីសេវា និងបញ្ហាសង្គមមួយចំនួន។

## ឯកសារយោង


Baker, Jacqui, and Sarah Milne. 2019. "Cambodia's Anticorruption Regime 2008-2018: A Critical Political Economy Approach." www.u4.no/publications/cambodias-anti-corruption-regime-2008-2018-a-critical-political-economy-approach.pdf.

Baudinet, Marc. 2018. *Cambodia in the Twenty-First Century: A Short Social Study*. Phnom Penh: Marc Baudinet.

Domashneva, Helena. 2013. "NGOs in Cambodia: It's Complicated." *The Diplomat*, 3 Dec 2013. https://thediplomat.com/2013/12/ngos-in-cambodia-its-complicated/.

Eng Netra, Ang Len, So Hengvotey, Hav Echoing, Chhom Heavy. 2019. *Cambodia's Young and Older Generation: Views on Generational Relations and Key Social and Political Issues*. CDRI Working Paper Series No. 116. Phnom Penh: Cambodia Development Resource Institute.

MOWA (Ministry of Women's Affairs). 2014. Neary Rattanak IV: Strategic plan (2014 – 2018) for Gender Equality and the Empowerment of Women in Cambodia. Phnom Penh.

Saphon Somolireasmey. 2015. "Women, Invisibility and Culture in Cambodian Society." PhD dissertation, University of Oviedo, Spain.

Scheer, Catherine. 2017. "New Life in an Expanding Market Economy: Moral Issues among Cambodia's Highland Protestants." In *"New Religiosities, Modern Capitalism, and Moral Complexities in Southeast Asia"*, edited by Juliette Koning and Gwenaël Njoto-Feillard, 65–88. Singapore: Palgrave.

Thon Theary. 2017. *A Proper Woman*. Phnom Penh: Self-published.

Tokuda, Yasuharu, Seiji Fujii and Takashi Inoguchi. 2010. "Individual and Country-Level Effects of Social Trust on Happiness: The Asia Barometer Survey." *Journal of Applied Social Psychology* 40 (10): 2574–2593.

Un Leang, Saphon Somolireasmey and Sok Serey. 2019. *Gender Analysis of Survey on Cambodia's Young and Older Generation: Family, Community, Political Knowledge and Attitudes, and Future Expectations.* Working Paper Series XXX. Phnom Penh: CDRI.

Zucker, Eve Monique. 2013. *Forest of Struggle: Moralities of Remembrance in Upland Cambodia*. Honolulu: Hawaii University Press.